**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៦៧. សសរ

ការិយាល័យរដ្ឋបាល

មកដល់ថ្ងៃទី 25.11.10 ម៉ោង 10.50

# សេចក្តីសម្រេច

## ស្តីពី

## ការចាត់តាំងកសាងស្តូបរំលឹកវិញ្ញាណក្ខន្ធប្រជាជន

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ ១.-**

ត្រូវបានចាត់តាំងកសាងស្តូបរំលឹកវិញ្ញាណក្ខ័ន្ធប្រជាជន ដែលបានបាត់បង់ជីវិតក្នុងឧបទ្ទវហេតុនាស្ពានកោះពេជ្រ យប់ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១០ ដើម្បីរំលឹកនិងចងចាំជានិច្ចនូវសោកនាដកម្មយ៉ាងធ្ងន់ធ្ងរ ចំពោះជាតិ និង ប្រជាជនកម្ពុជា ។

**ប្រការ ២.-**

ត្រូវបានប្រគល់ភារកិច្ចជូនឯកឧត្តម អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ រៀបចំជ្រើសរើសទីកន្លែងនៅក្បែរស្ពានកោះពេជ្រកន្លែងកើតឧបទ្ទវហេតុដើម្បីសាងសង់ស្តូបរំលឹកវិញ្ញាណក្ខន្ធប្រជាជន ដែលបានបាត់បង់ជីវិត។

**ប្រការ ៣.-**

ចំពោះថវិកាកសាងស្តូប គឺប្រើប្រាស់ថវិការបស់មូលនិធិវិទ្យុ និងទូរទស្សន៍បាយ័ន និងមូលនិធិទូរទស្សន៍ CTN ។

**ប្រការ ៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធនិងឯកឧត្តមអភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញត្រូវអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ ២០១០*

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ស្ថានីយ វិទ្យុ និងទូរទស្សន៍ បាយ័ន*
- *ស្ថានីយទូរទស្សន៍ CTN*
- *ដូចក្នុងប្រការ ៤*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*